## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## រវាង
## ក្រុមហ៊ុន ម៉ាស្ទ័រ&ហ្វ្រែង ( ខេមបូឌា)ខូអិលធីឌី
## ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ៨ និង ៣០នាទីព្រឹក នៅក្នុងរោងចក្រ **ម៉ាស្ទ័រ&ហ្វ្រែង ( ខេមបូឌា)ខូអិលធីឌី** មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន តំណាងកម្មករ និយោជិត និងប្រធានក្រុម ។ នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថាភាព បច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលឱ្យសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ ។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ៩២ នាក់ ( ស្រី ៥៣ នាក់ ) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១០៧ នាក់ ( ស្រី ៦២ នាក់ ) ។ រយៈពេល ០៨ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ។ ហើយក្នុងកំឡុងពេលព្យួរការងារនេះ កម្មករ និយោជិតបានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឧបត្ថម ១៥ដុល្លារសហរដ្ឋអាមេរិក ក្នុងរយៈពេល ០៨ថ្ងៃ។ ក្រុមហ៊ុននិងបើកប្រាក់ឧបត្តមក្នុងកំឡុងព្យួរកិច្ចសន្យាការងារនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ។

អង្គប្រជុំបានចប់នៅវេលាម៉ោង ០៩ និង ៥៥នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

ថ្ងៃច័ន្ទ ១៣រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

កណ្តាល,ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

**តំណាងក្រុមហ៊ុន**

## ស្នាមមេដៃតំណាងកម្មករ និយោជិត
## កិច្ចព្រមព្រៀង
## រវាង
## ក្រុមហ៊ុន ម៉ាស្ទ័រ&ហ្វ្រែង ( ខេមបូឌា)ខូអិលធីឌី
## ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

ប៉ែន ម៉ូលីនាថ អ៊ុន ភីន ជឿន ចឹម និន ធារិទ្ធ

ខៀវ សារ៉ែន ស៊ុន សុខហេង យឹម ថេ ថៃ រស្មី